ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ដំណាំដំឡូងមី






រៀបចំដោយ
នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ
ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.)


ខែកក្កដា ឆ្នាំ២០២៥


023 220 811
023 220810
070 463 219
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

**មាតិកា**

**១-សេចក្តីផ្តើម** ..... ១
**២-ការអនុវត្តការដាំដុះ** ..... ១
ក- ការរៀបចំដី ..... ១
ខ- ការជ្រើសរើសពូជ ប្រភេទពូជ កម្រិតម្សៅ និងប្រភពពូជដំឡូង ..... ១
គ- ពូជដែលត្រូវណែនាំដាំដុះនៅប្រទេសកម្ពុជា ..... ២
ឃ. ពេលវេលានៃការដាំដុះ ..... ៣
ង. របៀបនៃការដាំដុះ ..... ៣
ច. ការរក្សាគុណភាពដី ..... ៤
**៣-ការថែទាំ** ..... ៥
ក- ការស្រោចស្រព ..... ៥
ខ- ការដាក់ជីបំប៉ន ..... ៦
គ- ការសម្អាតស្មៅ ..... ៧
ឃ- កត្តាសត្វល្អិត ជំងឺ និងការបង្ការ ..... ៧
**៤-ការប្រមូលផល** ..... ១១
ក- អាយុកាលប្រមូលផល ..... ១១
ខ- ការគណនាកម្រិតម្សៅ ..... ១២
**៥-ការវិភាគសេដ្ឋកិច្ចលើការដាំដំឡូងមីលើផ្ទៃដី១ហិកតា** ..... ១៣
ក. ករណីសិក្សានៅខេត្តព្រះវិហារ ..... ១៣
ខ. ករណីសិក្សានៅខេត្តត្បូងឃ្មុំ ..... ១៦
គ- ករណីសិក្សានៅស្រុកសំឡូត ខេត្តបាត់ដំបង ..... ១៨
**៦-បញ្ហាប្រឈម** ..... ២១
**៧-អនុសាសន៍សម្រាប់កសិករដាំដំឡូងមី** ..... ២២
**៨-សេចក្តីសន្និដ្ឋាន** ..... ២៤
**៩-ប្រភពឯកសារ** ..... ២៤

# ដំណាំដំឡូងមី

## ១-សេចក្តីផ្តើម

ដំឡូងមីជាដំណាំដែលកំពុងដាំដុះដោយកសិករខ្នាតតូច។ ការកើនឡើងនូវសត្វល្អិតចង្រៃ និង ជំងឺគឺជាកត្តាដែលធ្វើឱ្យប៉ះពាល់ដល់ទិន្នផល។ ជាវិធានការគឺតម្រូវឱ្យអ្នកដាំដុះមានចំណេះដឹងល្អ និង អនុវត្តន៍ការគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដូចជា÷ គ្រប់គ្រងការរៀបចំដី ការដាំដុះ ការថែទាំ ការប្រើប្រាស់ ធាតុចូល ដង់ស៊ីតេដាំដុះ ការកម្ចាត់ជំងឺនិងស្មៅចង្រៃ ការជ្រើសរើសពូជ និងការប្រមូលផលជាដើម ដែលជាមូលដ្ឋានគ្រឹះសម្រាប់កសិករទទួលបានជោគជ័យ ទទួលបានទិន្នផលល្អ បានប្រាក់ចំណូលខ្ពស់។

ក្នុងគោលបំណងចូលរួមជួយបង្កើនសមត្ថភាពបច្ចេកទេសដល់កសិករដាំដុះដំណាំដំឡូងមី អាច ដោះស្រាយបញ្ហាប្រឈម កាត់បន្ថយហានិភ័យលើផលិតកម្ម កាត់បន្ថយការចំណាយថ្លៃដើម ក្រុមការងារ បច្ចេកទេសនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានរៀបចំគម្រោងអាជីវកម្មដំណាំដំឡូងមី ដោយ ចុះសិក្សាស្វែងយល់ពីបទពិសោធន៍ និងបញ្ហាប្រឈមជាក់ស្តែងពីកសិករដែលដាំដុះដំឡូងមីផ្ទាល់នៅ ខេត្តព្រះវិហារ ត្បូងឃ្មុំ និងខេត្តបាត់ដំបង។ គម្រោងនេះ ក៏បានសិក្សារៀបចំនូវតារាងចំណូល-ចំណាយ និងការវិភាគសេដ្ឋកិច្ចនៃការដាំដុះដំឡូងមីលើផ្ទៃដី១ហិកតា។

## ២-ការអនុវត្តការដាំដុះ

**ក-ការរៀបចំដី÷**ត្រូវភ្ជួរដីឱ្យបានជម្រៅប្រហែលពី ០.២៥ម៉-០.៣០ម៉ ចំនួន២ដង ដើម្បីឱ្យដីធូរ ល្អ បន្ទាប់មកត្រូវរើសស្មៅចេញ និងហាលដីឱ្យក្រៀមរយៈពេលពី ៧-១០ថ្ងៃ ធ្វើរបៀបនេះគឺដើម្បីកាត់ បន្ថយអត្រាកើតជំងឺ និងសត្វល្អិតមួយចំនួនចេញពីដី។ ភ្ជួរលើករងដែលមានទទឹង០.៨ម៉-១ម៉ និងកម្ពស់ ០.២ម៉-០.៣ម៉។ ការដាំដំឡូងមីត្រូវទុកចន្លោះគុម្ពពី ០.៥ម៉-០.៨ម៉ ដោយអាស្រ័យទៅតាមប្រភេទដីមាន ជីជាតិល្អ ឬមិនសូវមានជីជាតិ។ ការដាំដើមដំឡូងមីកៀកគ្នាទទួលបានមើមតូចៗ បើដាំរង្វើលអាចទទួល បានមើមធំជាង។

### ខ- ទិន្នផលស្រស់ កម្រិតម្សៅ និងប្រភពពូជដំឡូង

តារាងខាងក្រោមនេះបង្ហាញពីប្រភេទពូជដំឡូងមីដែលកសិករកម្ពុជា និងកសិករប្រទេសក្នុងតំបន់ និយមដាំ ដែលកសិករអាចមានជម្រើសរើសយកពូជណាមួយដែលសមស្របដូចខាងក្រោមនេះ÷

| ល.រ | ប្រភេទពូជ | ទិន្នផលមើមស្រស់ (តោន/ហ.ត) | កម្រិតម្សៅ (%) | ប្រភពពូជ |
|---|---|---|---|---|
| ១ | ដំឡូងគ | 11 | 22.4 | កម្ពុជា |
| ២ | ខេយូ៥០ (KU50) | 55 | 27.8 | ប្រទេសថៃ |

| | | | | |
|---|---|---|---|---|
| ៣ | ហោយបុង៦០ (Huay Bong60) | 54 | 29.2 | ប្រទេសថៃ |
| ៤ | អេសស៊ី៨ (SC8) | 51 | 26 | ប្រទេសចិន |
| ៥ | អេសស៊ី៩ (SC9) | 42 | 27.3 | ប្រទេសចិន |
| ៦ | អេសស៊ី៥ (SC5) | 40 | 28.4 | ប្រទេសចិន |
| ៧ | រ៉ៃយ៉ុង១ (Rayong1) | 40 | 25.2 | ប្រទេសថៃ |
| ៨ | រ៉ៃយ៉ុង៩០ (Rayong90) | 37 | 31.4 | ប្រទេសថៃ |
| ៩ | ខេអឹម៩៨-១ (KM 98-1) | 36 | 31.7 | វៀតណាម |
| ១០ | រ៉ៃយ៉ុង៦០ (Rayong60) | 35 | 28.2 | ប្រទេសថៃ |
| ១១ | រ៉ៃយ៉ុង៩ (Rayong9) | 35 | 31.4 | ប្រទេសថៃ |
| ១២ | អូអឹមអ (OMR 36.31.1) | 34 | 28.9 | ចិន |
| ១៣ | រ៉ៃយ៉ុង៧ (Rayong7) | 30 | 30.4 | ថៃ |
| ១៤ | បាត្រង់ (Batrang) | 30 | 26.9 | វៀតណាម |
| ១៥ | រ៉ៃយ៉ុង៧២ (Rayong72) | 30 | 31.2 | ថៃ |
| ១៦ | អេសស៊ី២០១ (SC 201) | 30 | 23 | ចិន |
| ១៧ | ណេនស៊ី១៩៩ (Nanzhi199) | 29 | 29.5 | ចិន |
| ១៨ | ណែប (NEP) | 25 | 25.3 | វៀតណាម |
| ១៩ | ជីអ៨៩១ (GR891) | 25 | 27.9 | វៀតណាម |
| ២០ | រ៉ៃយ៉ុង៥ (Rayong5) | 18 | 31.2 | ថៃ |

**ប្រភព÷ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៤**

### គ- ពូជដែលត្រូវបានណែនាំឱ្យដាំនៅក្នុងប្រទេសកម្ពុជា

ភាពបន្សាំនៃពូជដំឡូងមីតាមរយៈការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ និងផ្សព្វផ្សាយដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានការចូលរួមពីកសិករ អ្នកស្រាវជ្រាវ និងភ្នាក់ងារផ្សព្វផ្សាយបានផ្តល់ជម្រើសមួយចំនួនដល់កសិករកម្ពុជាឱ្យសាកល្បងដាំពូជទំនើបៗដូចជា÷ខេយូ៥០ រ៉ៃយ៉ុង១ រ៉ៃយ៉ុង៦០ រ៉ៃយ៉ុង៧២ រ៉ៃយ៉ុង៧ និងហោយបុង៦០។

- ពូជ ខេយូ៥០ ( KU50)÷ ត្រូវបានដាក់ឱ្យដាំដុះនៅឆ្នាំ ១៩៩២ ក្នុងប្រទេសថៃ ជាពូជដែលពេញនិយមនៅប្រទេសថៃ។ នៅប្រទេសវៀតណាមត្រូវបានស្គាល់ថាជាពូជខេអិម ៩៤ (KM94) ខណៈកសិករកម្ពុជាមួយចំនួនស្គាល់ថាពូជម៉ាឡេ។ ពូជនេះមានទងស្លឹកពណ៌បៃតងលាយផ្កាឈូក ត្រួយពណ៌ស្វាយ សំបកមើមពណ៌ត្នោតភ្លឺនិងសាច់មើមពណ៌ស។

➢ ពូជ រ៉ៃយ៉ុង១ (Rayong1)÷ ត្រូវបានបញ្ចេញនៅឆ្នាំ១៩៧៥ ក្នុងប្រទេសថៃ។ ពូជនេះមានទងស្លឹកជាពណ៌បៃតងលាយផ្កាឈូក ត្រួយពណ៌ស្វាយ និងដើមពណ៌ត្នោតស្រាល ហើយសាច់មើមពណ៌ស។

➢ ពូជ រ៉ៃយ៉ុង៦០ (Rayong60)÷ ត្រូវបានបញ្ចេញនៅឆ្នាំ១៩៨៧ ក្នុងប្រទេសថៃ។ ពូជនេះមានទងស្លឹកជាពណ៌បៃតងលាយផ្កាឈូក ត្រួយពណ៌បៃតង និងដើមពណ៌ត្នោតស្រាល ហើយសាច់មើមពណ៌ស។

➢ ពូជ រ៉ៃយ៉ុង៧២ (Rayong72)÷ ត្រូវបានបញ្ចេញនៅឆ្នាំ២០០០ ក្នុងប្រទេសថៃ។ ពូជនេះមានទងស្លឹកជាពណ៌ក្រហមលាយស្វាយ ត្រួយពណ៌ស្វាយ និងដើមពណ៌ត្នោត ហើយសាច់មើមពណ៌ស។

➢ ពូជ ហោយបុង៦០ (Huay Bong60)÷ ត្រូវបានបញ្ចេញនៅឆ្នាំ២០០៣ ក្នុងប្រទេសថៃ។ ពូជនេះ មានទងស្លឹកជាពណ៌បៃតងលាយផ្កាឈូក ត្រួយពណ៌ស្វាយ និងដើមពណ៌ត្នោត ហើយសាច់មើមពណ៌ស។

**ឃ-ពេលវេលានៃការដាំដុះ÷** ពេលវេលាដាំដុះដែលសមស្របបំផុតគឺនៅចន្លោះខែមីនា-មិថុនា។ ដំឡូងមីអាចផ្ដល់ផលនៅអាយុចន្លោះពី៩ខែ ទៅ១២ខែ។

**ង.របៀបនៃការដាំដុះ÷** អាចដាំដោយរបៀប៣យ៉ាងគឺ÷ ដាំផ្ដេក ដាំបញ្ឆិត(ទ្រេត) និងដាំបញ្ឈរ។

➢ ការដាំផ្ដេក÷ ដាក់កំណាត់ដើមដំឡូងមីកប់ក្នុងរណ្ដៅលើរងជម្រៅពី៥-១០ស.ម តាមបណ្ដោយ ឬទទឹងរង។ ការដាំបែបនេះនាំឱ្យចុះមើមនៅជម្រៅរាក់ជាងដាំបញ្ឆិតឬដាំបញ្ឈរនិងល្បឿននៃការដាំយឺតជាងការដាំបញ្ឆិត (ទ្រេត) ឬបញ្ឈរ។ ការដាំផ្ដេកអាចធ្វើឱ្យដើមដំឡូងដុះលូតលាស់ច្រើន តែមានមើមភាគច្រើនទំហំតូច។

**ការដាំដំឡូងមីផ្ដេក**




**ការដាំដំឡូងមីទ្រេត**




➢ ដាំបញ្ឆិត (ទ្រេត)÷ត្រូវយកកំណាត់ដើមដំឡូងមីដោតលើបណ្ដោយរង (មុំទេរ ៤៥-៦០ដឺក្រេ)។ ការដាំបែបនេះ ដំឡូងមីចាក់ឫស និងចុះមើមបានធំៗហើយបានតែមួយចំហៀង។ ដើមដំឡូងមីអាចដុះមែកតូចៗច្រើនជាងដាំបញ្ឈរ។

➢ ដាំបញ្ឈរ÷ ត្រូវយកកំណាត់ដំឡូងមីដោតត្រង់ឡើងលើ ៩០ដឺក្រេលើបណ្ដោយរង។ ដំឡូងមីដែលដាំបញ្ឈរផលិតមើមបានជុំវិញដើម ទិន្នផលខ្ពស់ជាងដាំផ្ដេក និងដាំបញ្ឆិត ហើយធន់នឹងភាពរាំងស្ងួតព្រោះឫសចាក់បានជ្រៅ។



ការដាំដំឡូងមីបញ្ឈរ






## ច. ការរក្សាគុណភាពដី

-លាមកសត្វ និងកាកសំណល់ផ្សេងៗ÷ លាមកសត្វ កាកសំណល់ផ្ទះបាយ និងកម្ទេចកម្ទីរុក្ខជាតិគឺត្រូវប្រមូលរក្សាទុកសម្រាប់ប្រើប្រាស់ក្នុងចម្ការដំឡូងមីដើម្បីបំពេញឡើងវិញនូវសារធាតុចិញ្ចឹមដែលបាត់បង់ក្រោយប្រមូលផល។

-ជីស្រស់÷ ជីស្រស់ដែលបានមកពីដំណាំគម្របដីដូចជាពពួកសណ្ដែក សុទ្ធតែអាចចាប់អាសូតពីបរិយាកាសចូលទៅក្នុងដី។ ដំណាំសណ្ដែកអង្គុយអាចផ្ដល់អាសូតជាមធ្យម៨០គីឡូក្រាម/ហិកតាទៅឱ្យដីបន្ទាប់ពី៨-១០សប្ដាហ៍ក្រោយពេលដាំ ហើយត្រូវភ្ជួរលុបទៅក្នុងដីក្លាយជាជីសរីរាង្គដែលដំឡូងមីអាចស្រូបសារធាតុចិញ្ចឹមបាន។

-ការដាំដំណាំបង្វិល÷ ការដាំដំឡូងមីដដែលៗលើចម្ការតែមួយរៀងរាល់ឆ្នាំ នាំឱ្យដីបាត់បង់ជីជាតិតាមរយៈការប្រមូលផលមើម ដើម ព្រមទាំងបង្កើនកត្តាចង្រៃដូចជាសត្វល្អិត និងជំងឺជាដើម។ កសិករគួរប្ដូរមុខដំណាំរៀងរាល់ ១-២ឆ្នាំម្ដង ដោយការដាំដំណាំបង្វិលដែលអាចជួយបង្កើនជីជាតិដី កាត់បន្ថយសំណឹកដី បន្ថយជំងឺ-សត្វល្អិត និងបង្កើនទិន្នផលដំណាំនៅរដូវកាលបន្ទាប់។ កសិករមិនត្រូវដាំដំណាំប្រភេទមើមដូចគ្នាទេដោយសារតែដំណាំទាំងនេះស្រូបសារធាតុចិញ្ចឹមដូចៗគ្នា។



-ការដាំដំណាំឆ្លាស់÷ ដំណាំឆ្លាស់ជួយដល់ការប្រើប្រាស់ដីអស់លទ្ធភាព ពិពិធកម្មដំណាំដូចជាពពួកសណ្តែកដែលជួយដល់ការបង្កើនចំណូលថវិកាគ្រួសារ ការបន្ថែមជីជាតិដីតាមបែបធម្មជាតិ និងបន្ថយការដុះដាលនៃស្មៅចង្រៃមួយចំនួនក្នុងចម្ការ។



ដំឡូងមីដាំឆ្លាស់ជាមួយសណ្តែកសៀង



ដំឡូងមីដាំឆ្លាស់ជាមួយសណ្តែកដី



ដំឡូងមីដាំឆ្លាស់ជាមួយពោត

**ការដាំដំណាំឆ្លាស់ក្នុងចម្ការដំឡូងមី**

-ការពិសោធន៍ដី ១-២ឆ្នាំម្តង÷ កំណត់នូវបរិមាណសារធាតុចិញ្ចឹម និងកម្រិតប៉េហាស់ (pH) ដី ដើម្បីបានអនុសាសន៍នៃការប្រើប្រាស់ជីឱ្យបានត្រឹមត្រូវ និងការរៀបចំចាត់ចែងចំណាយឱ្យចំគោលដៅ។ ជាទូទៅ pH សមស្របសម្រាប់ដំណាំដំឡូងមីចន្លោះពី៥.៥-៦.៥ ព្រោះកម្រិតនេះដំឡូងមីអាចស្រូបសារធាតុចិញ្ចឹមបានល្អ។ តែបើប៉េហាស់ក្រោម ៥.៥ កសិករត្រូវបាចកំបោរកសិកម្ម និងបន្ថែមជីសរីរាង្គដើម្បីកែប្រែគុណភាពដី។ pH របស់ដីមានឥទ្ធិពលទៅលើបរិមាណសារធាតុចិញ្ចឹមដែលអាចរលាយជាមួយទឹកក្នុងដី និងលទ្ធភាពស្រូបជីជាតិដោយរុក្ខជាតិ។



**ការវាស់ pH ដី**



**ការទប់ការហូរច្រោះ**

-ទប់ស្កាត់ការហូរច្រោះដី÷ ១)រក្សាជម្រាលកុំចោតខ្លាំងតាមដែលអាចធ្វើបាន ២)ដាំរុក្ខជាតិតូចៗ ពពួកសណ្តែកជារបាំងដែលអាចជួយបន្ថយល្បឿនទឹកហូរពីទីខ្ពស់ ៣)ជីកចង្អូរព័ទ្ធជុំវិញដើម្បីបញ្ចៀសទឹកកុំឱ្យហូរកាត់ចម្ការ។ ប្រយោជន៍នៃការទប់ស្កាត់ការហូរច្រោះមានដូចជា÷ រក្សាបាននូវសារធាតុចិញ្ចឹមក្នុងដី និងជីដែលកសិករបានដាក់ (ជីលាមកសត្វ ជីស្រស់ ជីកំប៉ុស និងជីគីមី) មិនឱ្យបាត់បង់តាមរយៈការហូរច្រោះតាមទឹក។

### ៣-ការថែទាំ

**ក-ការស្រោចស្រព÷** ត្រូវត្រៀមប្រភពទឹកសម្រាប់ស្រោចស្រពដូចជា ទឹកអូរ ស្រះ បឹង ទឹកអណ្តូងក្រោមដី (អណ្តូងខួង)។ ចំពោះទឹកក្រោមដី បើអាចគួរឱ្យអ្នកជំនាញពិនិត្យមុនប្រើប្រាស់ជៀសវាងខូចដំណាំ ឬបូមស្តុកក្នុងស្រះយ៉ាងតិច២៤ម៉ោងមុនស្រោចដំណាំ។ ប្រព័ន្ធស្រោចស្រពសមស្របសម្រាប់ដំណាំដំឡូងមី គឺប្រព័ន្ធដំណក់(Drip Irrigation)ព្រោះជួយសន្សំសំចៃទឹក កាត់បន្ថយស្មៅចង្រៃ និងមានប្រសិទ្ធភាពខ្ពស់។ ដំឡូងមីជាដំណាំដែលធន់នឹងភាពរាំងក្រៀមដោយសារឫសរបស់វាចាក់ដល់ស្រទាប់ដីសើមខាងក្រោម ហើយមើមរបស់វាមានតួនាទីរក្សាលំនឹងជាតិទឹកបានល្អ។ កម្រិតនៃការស្រោចស្រពគឺ ១លីត្រ/២ថ្ងៃ/ដើម សម្រាប់រដូវប្រាំង បើរដូវវស្សាមិនចាំបាច់ស្រោចទេ។ កសិករអាចបញ្ចូលទឹកតាមចង្អូររងបាន តែត្រូវការប្រើទឹកច្រើន និងមិនសូវសន្សំសំចៃ។



១-ការស្រោចស្រពដោយប្រព័ន្ធដំណក់



២-ការបង្ហូរទឹកតាមចង្អូររង



៣-មិនមានការស្រោចស្រព

**ខ-ការដាក់ជី**

- ការប្រើប្រាស់ជីឱ្យមានតុល្យភាព និងការគ្រប់គ្រងជីជាតិដី គឺមានសារសំខាន់ខ្លាំងចំពោះដំណាំដំឡូងមី ដោយអាចទទួលបានទិន្នផលខ្ពស់ជាច្រើនឆ្នាំលើផ្ទៃដីចម្ការដដែល។ ដើម្បីរក្សាបាននូវទិន្នផលពី៣០-៤០តោន/ហិកតា ជាទូទៅបរិមាណសមស្របចំពោះការប្រើប្រាស់ជីសម្រាប់ដំណាំដំឡូងមី គឺ÷ ជីអ៊ុយរ៉េ (៤៦:០០:០០) ១០០គីឡូក្រាម/ហិកតា + ដេអាប៉េ (១៨:៤៦:០០)៥០គីឡូក្រាម/ហិកតា + ១០០គីឡូក្រាមនៃប៉ូតាស្យូម(០០:០០:៦០)/ហិកតា តែអាស្រ័យកម្រិតជីជាតិដី និងការថែទាំផងដែរ។ ចំពោះបរិមាណជីលាមកសត្វ ឬជីកំប៉ុសគួរដាក់ពី ៦-៧តោន/ហិកតា។

-<u>ការដាក់ជីចំពោះដីល្បាយខ្សាច់ (មិនសូវមានជីជាតិ)</u>÷ដីប្រភេទនេះមានកម្រិតជីជាតិទាប ងាយបាត់បង់សារធាតុចិញ្ចឹម ជាពិសេសអាសូត(N) និងប៉ូតាស្យូម(K) ដូច្នេះដីនេះត្រូវការជីក្នុងបរិមាណច្រើនជាងដីប្រភេទផ្សេងៗដូចជាដីក្រហម និងដីខ្មៅជាដើម។ ការប្រើប្រាស់ជីក្នុងការដាំដុះ÷

- ជីទ្រាប់បាតមុនពេលដាំឬពេលដាំគឺ÷ ជី NPK (១៥-១៥-១៥): ២០០គីឡូក្រាម/ហិកតា
- អាយុពី ៣០ - ៤៥ ថ្ងៃក្រោយដាំ ដោយប្រើអ៊ុយរ៉េ (៤៦ : ០ : ០ ) ១០០គីឡូក្រាម/ហិកតា
- អាយុពី ៧៥- ៩០ថ្ងៃក្រោយដាំប្រើជីប៉ូតាស្យូម (០: ០: ៦០) ១០០គីឡូក្រាម/ហិកតា។

-ដីឥដ្ឋល្បាយខ្សាច់(ដីមានជីជាតិមធ្យម)÷ ដីប្រភេទនេះមានជីជាតិល្អប្រសើរជាងដីល្បាយខ្សាច់ អាចរក្សាសំណើម និងសារធាតុចិញ្ចឹមបានល្អ

- ជីទ្រាប់បាត(មុនពេលដាំ ឬពេលដាំ) NPK (១៥-១៥-១៥)១៥០គីឡូក្រាម/ហិកតា
- ជីបំប៉នលើកទី១ (៤៥ - ៦០ ថ្ងៃក្រោយដាំ): អ៊ុយរ៉េ (៤៦: 0: 0) ៩០គីឡូក្រាម/ហិកតា និងជីប៉ូតាស្យូម (00: 00: ៦0)៦0 គីឡូក្រាម/ហិកតា
- ជីបំប៉ននៅអាយុពី ៩0- ១២០ថ្ងៃប្រើជីប៉ូតាស្យូម ( 00: 00: ៦0)៧0 គីឡូក្រាម/ហិកតា។

-ដីឥដ្ឋធួន់ (ដីខ្មៅឬដីក្រហមមានជីជាតិខ្ពស់)÷ ដីប្រភេទនេះជាទូទៅមានជីជាតិខ្ពស់ និងអាចផ្គត់ផ្គង់សារធាតុចិញ្ចឹមបានច្រើន។ ការដាក់ជីត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាងការលើសជី។

- ជីទ្រាប់បាត(មុនពេលដាំ ឬក្នុងពេលដាំ): NPK (១៥-១៥-១៥):១៥០គីឡូក្រាម/ហិកតា (អាចផ្តោតលើជី ផូស្វ័រ និងប៉ូតាស្យូម)។
- ជីបំប៉ននៅអាយុពី៤៥ -៧៥ ថ្ងៃក្រោយដាំ: អ៊ុយរ៉េ (៤៦: 00: 00)៧0គីឡូក្រាម/ហិកតា និងជីប៉ូតាស្យូម (00: 00: ៦0) ៥0 គីឡូក្រាម/ហិកតា។

សម្គាល់÷ ដើម្បីដាក់ជីឱ្យបានត្រឹមត្រូវ និងបង្ការការដាក់ជីលើស ឬខ្វះ កសិករគួរយកដីទៅមន្ទីរពិសោធន៍រកកម្រិតសារធាតុចិញ្ចឹមក្នុងដីជាមុនសិន នោះអ្នកជំនាញនឹងណែនាំកម្រិតជីដែលត្រូវប្រើសមស្របនឹងប្រភេទដី និងកម្រិតជីជាតិដែលមានក្នុងដីស្រាប់។

**គ-ការសម្អាតស្មៅ÷** ការបាញ់ស្មៅត្រូវធ្វើឡើងក្រោយពីដាំបាន១ខែកន្លះទៅ២ខែដើម្បីកាត់បន្ថយការប្រជែងស្រូបសារធាតុចិញ្ចឹម ពន្លឺ និងទឹកជាមួយដើមដំឡូងមី។ បើទុកស្មៅមិនបានជម្រះរហូតដល់ខែទី៣ អាចនឹងថយចុះទិន្នផលដំឡូងមីរហូតដល់ ៥0%។

ការបាញ់ថ្នាំស្មៅត្រូវធ្វើយ៉ាងតិច២ដងរហូតដល់ស្លឹកដំឡូងមីលូតលាស់គ្របជិតលើរង។ កសិករអាចសម្អាតស្មៅដោយប្រើកម្លាំងពលកម្ម និងប្រើថ្នាំស្មៅដែលសមស្របសម្រាប់ដំណាំដំឡូងមី ដោយមិនប៉ះពាល់ដល់ការលូតលាស់ និងអាចចំណេញពេលវេលា។



ការបាញ់ថ្នាំស្មៅចន្លោះរង

**ឃ-កត្តាសត្វល្អិត ជំងឺ និងការបង្ការ**

**ប្រភេទសត្វល្អិត÷** សត្វល្អិតដែលតែងតែកើតលើដំណាំដំឡូងមីមានដូចជា ចៃ (Aphids) ទ្រីប (Thrips) រុយស(White Flies) ចៃស ឬចៃម្សៅ។

- ពពួកចៃ (Aphids)÷សត្វល្អិតនេះតែងបំផ្លាញលើត្រួយខ្ចីៗនៅផ្ទៃស្លឹកខាងក្រោម ដោយបឺតរុក្ខរសដំឡូងមីធ្វើឱ្យស្លឹកមិនអាចធ្វើរស្មីសំយោគ និងស្រូបសារធាតុចិញ្ចឹមបាន អាចឱ្យដើមដំឡូងមីងាប់។ ពពួកចៃនេះខ្លួនមានទំហំតូចពណ៌លឿង ឬបៃតង។ វដ្តជីវិតរបស់ពួកវាមានរយៈពេលពី ២១-២៨ថ្ងៃ។

វិធានការ÷ ១)កសិករអាចប្រើពពួកប្រេដាទ័រដូចជា សត្វល្អិតអណ្តើកមាស ដើម្បីស៊ីបំផ្លាញពពួកចៃនេះ ២)អាចប្រើថ្នាំធម្មជាតិ ៣)លាយសាប៊ូជាមួយទឹកបាញ់លើចៃ៥០ក្រាម+១៦លីត្រទឹក ៤)ថ្នាំគីមី អាបាមេចទីន (Abamectin) ហ្វីប្រូនីល (Fipronil)។


ពពួកអាហ្វីដ ឬចៃលើស្លឹកដំឡូងមី

- ទ្រីប (Thrips)÷ ទ្រីបបំផ្លាញដំឡូងមីមានលក្ខណៈស្រួចស្រាវនៅរដូវក្តៅដោយពពួកនេះបឺតរុក្ខរសស្លឹកដែលនាំឱ្យការធ្វើរស្មីសំយោគថយចុះ។ វដ្តជីវិតទ្រីបមានរយៈពេលពី ១៤-២១ថ្ងៃ។

វិធានការ÷ ១)ត្រូវសម្អាតស្មៅជាប្រចាំដែលជាទីជម្រក ២)សម្អាតដំណាំចាស់ៗចេញពីចម្ការ ៣)ដាំដំណាំបង្វិល ៤)ប្រើថ្នាំគីមី Abamectin, Imidacloprid។


ពពួកទ្រីបលើស្លឹកដំឡូងមី

- រុយស÷ ដង្កូវ និងរុយសពេញវ័យរស់បានដោយការបឺតរុក្ខរសពីដំឡូងមី ដែលធ្វើឱ្យរាំងស្ទះដល់ការធ្វើរស្មីសំយោគ និងជាភ្នាក់ងារចម្លងជំងឺវីរុសផងដែរ។ វដ្តជីវិតរុយសមានរយៈពេលពី ២៨-៣៥ថ្ងៃ។

វិធានការ÷ ១)សម្អាតស្មៅ និងរុក្ខជាតិតូចៗដែលជាជម្រក ២) សាប៊ូលាងចាន ១០ម.ល+ប្រេងឆា ១០ម.ល+ទឹក១លីត្រ បាញ់លើរុយស និង៣) ប្រើថ្នាំគីមី Admire, Abamectin បាញ់លើកន្លែងបំផ្លាញ។


ពពួករុយសលើផ្ទៃខាងក្រោមស្លឹកដំឡូងមី

- ចៃស ឬចៃម្សៅ÷ ជាប្រភេទសត្វល្អិតដែលបំផ្លាញច្រើនជាងគេលើដំណាំដំឡូងមីជាពិសេស នៅ រដូវប្រាំងព្រោះសត្វនេះច្រើនកើតនៅពេលអាកាសធាតុក្តៅ និងក្រៀម។ រោគសញ្ញា ធ្វើឱ្យស្លឹកដំឡូងមីជ្រុះ ដើមធ្លាក់ខ្សោយ រួញត្រួយ ស្លឹកឡើងស្លេកខុសប្រក្រតី និងជ្រុះស្លឹកខុសពីធម្មតា ឬប្រែជាស្រពោន ហើយឡើងជាពណ៌លឿង។

វិធានការ÷ ១)ស្រោចទឹកនិងដាក់ជីឱ្យបានគ្រប់គ្រាន់ ២) សម្អាតស្មៅនិងរុក្ខជាតិជម្រក ៣)ប្តូរមុខដំណាំ ៤)ប្រើប្រាស់សត្រូវធម្មជាតិ ពពួកប្រេដាទ់រ អង្រ្កង ប៉ារ៉ាស៊ិត ផ្សិតបង្កជំងឺ ៥)ប្រើប្រាស់ថ្នាំពុលគីមីទៅតាមការណែនាំនៅសម្បកកញ្ចប់ ឬដប។



ពពួកចៃសលើផ្ទៃស្លឹក និងត្រួយខ្ចីដំឡូងមី

- ពីងពាងក្រហម÷ ជាប្រភេទសត្វល្អិតដែលបំផ្លាញស្លឹកដំឡូងមីនាំឱ្យប៉ះពាល់ទិន្នផលខ្លាំងព្រោះ ដំឡូងមិនអាចផលិតម្សៅបានច្រើន។សត្វល្អិតនេះតែងកើតនៅរដូវប្រាំងដែលមានអាកាសធាតុក្តៅក្រៀម។

វិធានការ÷ ម្ទេសចំនួន២០ក្រាម ត្រាំទឹក១លីត្រ រក្សាទុករយៈពេល ១ថ្ងៃ បន្ទាប់មកយកលាយជាមួយទឹក ៥លីត្រ ដើម្បីសម្លាប់សត្វដែលទើបញាស់។ ចំពោះថ្នាំពុលគីមីដែលអាចប្រើមានដូចជា **Spirodiclofen, Abamectin, Burofezin** ឬ **Propargite** កម្ចាត់ពងពីងពាងក្រហម។



ពពួកពីងពាងក្រហមលើស្លឹក និងត្រួយដំឡូងមី

**ប្រភេទជំងឺ÷** ជំងឺលើដំឡូងមីរួមមាន÷ ម៉ូសាអ៊ិច (Mosaic) រលួយមើម (Root Rot), ជំងឺបន្ទះពណ៌ត្នោត (Cassava Brown steak Disease), ជំងឺអុចត្នោត (Brown Leave Spot), ជំងឺខ្លោចស្លឹក (Blight Leave Spot) និងជំងឺអំបោសធ្មប់ (Witches Broom) ។

- ជំងឺម៉ូសាអ៊ិច (Cassava Mosaic Disease): បង្កឡើងដោយវីរុសធ្វើឱ្យប៉ះពាល់ដល់មើម ដើម និងស្លឹករបស់ដំឡូងមី។ ស្លឹកឡើងរួញកណ្ដាញ់ប្រែជាពណ៌បៃតងលាយលឿង និងស។ ជំងឺនេះរាតត្បាតដោយសារភ្នាក់ងារចម្លងជំងឺសត្វល្អិតរុយស។

វិធានការ÷ ១)ត្រួតពិនិត្យចម្ការជាប្រចាំដោយត្រូវកម្ចាត់វត្ថុមានរុយស ២)មិនត្រូវដាំពូជដំឡូងមីដែលមានប្រភពពីចម្ការដែលធ្លាប់កើតជំងឺ។



ជំងឺម៉ូសាអ៊ិចដំឡូងមី

-ជំងឺបន្ទះពណ៌ត្នោត (Cassava Brown steak Disease) ÷ ជំងឺនេះបង្កឡើងដោយវីរុស Carla virus ដែលកើតលើស្លឹក ដើម និងមើម។ ស្លឹកឡើងពណ៌លឿងលាយបៃតង ដើមមានលេចស្នាមពណ៌ត្នោតចាស់រាងជាបន្ទះ ធ្វើឱ្យខូចទ្រង់ទ្រាយមើម និងសម្បកមើម។

វិធានការ÷ គាស់ដុតបំផ្លាញចោល និងមិនត្រូវយកដើមដែលមានជំងឺទៅដាំបន្តឡើយ។

ជំងឺបន្ទះពណ៌ត្នោតលើដំឡូងមី



-ជំងឺរលួយមើម (Root Rot)÷ ជំងឺនេះបង្កឡើងដោយពពួកផ្សិត Phytophthora បណ្ដាលឱ្យមានការបាត់បង់ទិន្នផល។ មូលហេតុនៃការកើតជំងឺនេះ គឺការស្រោចទឹកហួសប្រមាណ ឬមានភ្លៀងច្រើនដក់ទឹកក្នុងចម្ការអំឡុងពេលចុះមើម។ មើមដំឡូងមីកើតជំងឺនេះមានពណ៌ត្នោតខាងក្នុងសាច់មើម ឬរលួយ។

វិធានការ÷ បើមានភ្លៀងខ្លាំងត្រូវកាយចង្អូរបង្ហូរទឹកចេញពីចម្ការឱ្យលឿនបំផុតដែលអាចធ្វើទៅបាន។

ជំងឺរលួយមើមដំឡូងមី



-ជំងឺអុចត្នោត (Brown Leave Spot)÷ ជំងឺនេះបង្កឡើងដោយផ្សិតឈ្មោះ Cercospora henningsii។ រោគសញ្ញាកើតលើស្លឹកដែលបណ្ដាលឱ្យខ្លោចងាប់ស្លឹកជាចំណុចៗ។

វិធានការ÷ កាត់ប្រមូលស្លឹកដែលកើតមានជំងឺទៅដុតបំផ្លាញចោល និងប្រើថ្នាំផ្សិតដែលមានធាតុសកម្ម Carbendazim បាញ់លើស្លឹកដំឡូងមី ។



ជំងឺអុចត្នោតលើដំឡូងមី

-ជំងឺខ្លោចស្លឹក (Blight Leave Spot)÷ ជំងឺនេះបង្កឡើងដោយផ្សិត Xanthomonas axonopodis លេចឡើងស្នាមអុចៗខ្លោចធំៗនៅលើស្លឹកដែលធ្វើឱ្យស្លឹកថយកម្រិតពណ៌បៃតង (Chlorophyll) ហើយលេចឡើងនូវម្សៅពណ៌សប្រផេះ ហើយស្លឹកឡើងក្រៀម ភាគច្រើននៅចន្លោះខែឧសភា-មិថុនា។



ជំងឺខ្លោចស្លឹកលើដំឡូងមី

វិធានការ÷ ប្រើប្រាស់ដីឱ្យមានតុល្យភាព ដីមិនដក់ទឹក ដាំដំណាំបង្វិល និងអាចប្រើថ្នាំ Antracol និង Propineb តាមកម្រិតណែនាំលើកញ្ចប់ថ្នាំ។

-ជំងឺអំបោសធ្មប់(Witches Broom)÷ ជំងឺបង្កឡើងដោយប៉ារ៉ាស៊ីតស្រដៀងនឹងបាក់តេរីឈ្មោះ Phytoplasma។ ជំងឺនេះអាចឆ្លងពីដើមមួយទៅមួយដោយសត្វល្អិត។ ដំឡូងមីដែលផ្ទុកជំងឺនេះមានការលូតលាស់ខុសប្រក្រតី ដោយមានបែកមែកតូចៗច្រើនដុះនៅផ្នែកខាងចុងនៃដើម។

វិធានការ÷ មិនត្រូវជ្រើសដើមដែលមានជំងឺធ្វើពូជបន្ត និងត្រូវគាស់ដើមដែលផ្ទុកជំងឺដុតបំផ្លាញចោល។



ជំងឺអំបោសធ្មប់លើដើមដំឡូងមី

## ៤-ការប្រមូលផល

### ក. អាយុកាលប្រមូល

មើមដំឡូងមីអាចប្រមូលផលនៅពេលមានអាយុយ៉ាងតិចពី៩ ទៅ១២ខែ ឬលើសនេះអាស្រ័យលើប្រភេទពូជ។ កសិករត្រូវប្រាកដថា មើមដំឡូងមីអាចមានកម្រិតភាគរយម្សៅគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវការអ្នកទិញ (កម្រិតភាគរយម្សៅដំឡូងមីដែលល្អស្ថិតនៅចន្លោះ ២០ ទៅ ៣២%)។

## ខ. ការគណនាកម្រិតម្សៅ

មុនពេលប្រមូលផលមើមដំឡូងមី កសិករត្រូវធ្វើការសាកល្បងវាស់កម្រិតម្សៅតាមប្រភេទពូជ។ ការគណនានេះធ្វើឱ្យកសិករអាចដឹងថាមើមដំឡូងមីមានម្សៅគ្រប់គ្រាន់ ហើយអាចប្រមូលផលបាន ឬអត់ ដើម្បីបង្ការការទម្លាក់ថ្លៃពីអ្នកប្រមូលទិញ។

**<u>នេះគឺរូបមន្តគណនាកម្រិតភាគរយម្សៅក្នុងមើមដំឡូងមី ÷</u>**

-រូបមន្តទី១ ÷ SC(%) = (SG x 210.8) - 213.4

-រូបមន្តទី២ ÷ SC(%) = (SG - 1.00906) ÷ 0.004845

**ទម្ងន់ជាក់លាក់** ÷ SG = Ma ÷ (Ma - Mw)

SG: Specific Gravity ទម្ងន់ជាក់លាក់

Ma: Weight of Cassava in Air = ទម្ងន់ដំឡូងមីថ្លឹងក្នុងខ្យល់ឬទម្ងន់ថ្លឹងធម្មតា

Mw: Weight of Cassava in Water = ទម្ងន់ដំឡូងមីថ្លឹងក្នុងទឹក

ចំពោះលេខ 210.8 &213.4 ឬ 1.00906 & 0.004845 ជាលេខមេគុណបន្ថែម

**ឧទាហរណ៍** ÷ ដំឡូងមីស្រស់ថ្លឹងក្នុងខ្យល់(ថ្លឹងធម្មតា)មានទម្ងន់៥,០០០ក្រាម ហើយពេលថ្លឹងក្នុងទឹក (ទឹកថ្លាល្អ)មានទម្ងន់ត្រឹមតែ ៦៥០ក្រាមប៉ុណ្ណោះ។

ការគណនាកម្រិតភាគរយម្សៅដំឡូងមីតាមរូបមន្តទាំង២ខាងលើ÷

ឧ. យើងមាន Ma = 5,000g, Mw = 650g

យើងមានមេគុណ 210.8 & 213.4 និង 1.00906 & 0.004845

គណនាទម្ងន់ជាក់លាក់ SG = Ma ÷ (Ma - Mw) = 5,000 ÷ (5000-650)

= 5,000 ÷ 4350 = 1.14943 ដូចនេះទម្ងន់ជាក់លាក់ SG = 1.14943

**តាមរូបមន្តទី១** ÷ ភាគរយកម្រិតម្សៅ SC (%) = (SG x 210.8) - 213.4

= (1.14943 x 210.8) - 213.4 ភាគរយកម្រិតម្សៅ SC (%) = 28.899%

**តាមរូបមន្តទី២** ÷ ភាគរយកម្រិតម្សៅ SC (%) = (SG - 1.00906) ÷ 0.004845

= (1.14943 - 1.00906) ÷ 0.004845 ភាគរយកម្រិតម្សៅ SC (%) = 28.972%

**ប្រភព**÷ កសិករនៃសមាគមន៍ដំឡូងមីខេត្តកំពង់ធំ

## ៥-ការវិភាគសេដ្ឋកិច្ចលើការដាំដំឡូងមីលើផ្ទៃដី១ហិកតា

### ក. ករណីសិក្សា÷ដំឡូងមីស្រស់នៅខេត្តព្រះវិហារ

❖ តារាងវិភាគសេដ្ឋកិច្ចដំឡូងមីស្រស់នៅខេត្តព្រះវិហារ

| ប្រភេទចំណាយ | ឯកតា | ចំនួន/ឯកតា | តម្លៃ/ឯកតា (រៀល) | សរុប/១ហ.ត (រៀល) |
|---|---|---|---|---|
| ការរៀបចំដី(ភ្ជួរ រាស់ លើករង) | ឈុត | 1 | 450,000 | 450,000 |
| ជី ១៥ - ១៥- ១៥ដាក់ពេលពូនរង | គ.ក | 150 | 3,000 | 450,000 |
| ថ្លៃដាំ | លើក | 1 | 240,000 | 240,000 |
| ពូជ | បាច់ | 250 | 4,000 | 1,000,000 |
| ថ្លៃបាញ់ និងថ្នាំស្មៅ (អាយុ២ខែកន្លះទៅ៣ខែ) | លើក | 1 | 40,000 | 40,000 |
| ជីបំប៉នលើទី១(អាយុ ៤៥-៧០ថ្ងៃក្រោយដាំ) | គ.ក | 150 | 3,000 | 450,000 |
| ថ្លៃថ្នាំសត្វល្អិត (ពេលដំឡូងអាយុ៣ខែ) | ឈុត | 1 | 75,800 | 75,800 |
| ជីបំប៉នលើទី២ (៩០-១២០ថ្ងៃ ក្រោយដាំ) | គ.ក | 90 | 3,000 | 270,000 |
| ថ្លៃថ្នាំសត្វល្អិត (ពេលដំឡូងអាយុ៤-៥ខែ) | ឈុត | 1 | 75,800 | 75,800 |
| ថ្លៃកាប់ដើម (១បាច់= ២៥ដើម) | បាច់ | 250 | 3,000 | 750,000 |
| ខ្សែចងដើមដំឡូង | ដុំ | 1 | 17,500 | 17,500 |
| ថ្លៃភ្ជួរគាស់មើម | លើក | 1 | 217,500 | 217,500 |
| ឈ្នួលប្រមូលដំឡូងមី និងលើកដាក់ឡាន១តោន= ៣៥,០០០រៀល (ទិន្នផល ៣០,០០០គ.ក/ហិកតា) | តោន | 30 | 35,000 | 1,044,000 |
| ថ្លៃដឹកទៅដល់សែឡូ ) | តោន | 30 | 23,000 | 696,000 |
| **សរុបចំណាយ** | | | | **5,776,600** |
| **ចំណូលពីការលក់ដើមដំឡូងមី** | បាច់ | 400 | 4,000 | **1,600,000** |
| **ចំណូលពីការលក់ដំឡូងមីស្រស់** | គ.ក | 30,000 | 220 | **6,600,000** |
| **លទ្ធផល** (ចំណេញ / ខាត) | | | | **2,423,400** |

**សម្គាល់÷** ជាតម្លៃនៅដើមឆ្នាំ២០២៥ ។ តម្លៃនេះអាចមានការប្រែប្រួលតាមតំបន់ផ្សេងៗគ្នា ។

❖ និន្នាការតម្លៃ ÷ សម្រាប់ទិន្នផលដំឡូងមីស្រស់៣០តោន/ហិកតា

| ទិន្នផល (គ.ក/ហិកតា) | តម្លៃ/គ.ក | និន្នាការចំណូល | ថ្លៃដើម/ហិកតា | ខាត- ចំណេញ/ហិកតា |
|---|---|---|---|---|
| 30,000 | 190 | 5,700,000 | 5,776,600 | -76,600 |
| 30,000 | 200 | 6,000,000 | 5,776,600 | 223,400 |
| 30,000 | 210 | 6,300,000 | 5,776,600 | 523,400 |
| 30,000 | 220 | 6,600,000 | 5,776,600 | 823,400 |

| | | | | |
|---|---|---|---|---|
| 30,000 | 230 | 6,900,000 | 5,776,600 | 1,123,400 |
| 30,000 | 240 | 7,200,000 | 5,776,600 | 1,423,400 |
| 30,000 | 250 | 7,500,000 | 5,776,600 | 1,723,400 |
| 30,000 | 260 | 7,800,000 | 5,776,600 | 2,023,400 |
| 30,000 | 270 | 8,100,000 | 5,776,600 | 2,323,400 |
| 30,000 | 280 | 8,400,000 | 5,776,600 | 2,623,400 |
| 30,000 | 290 | 8,700,000 | 5,776,600 | 2,923,400 |
| 30,000 | 300 | 9,000,000 | 5,776,600 | 3,223,400 |
| 30,000 | 310 | 9,300,000 | 5,776,600 | 3,523,400 |
| 30,000 | 320 | 9,600,000 | 5,776,600 | 3,823,400 |
| 30,000 | 330 | 9,900,000 | 5,776,600 | 4,123,400 |

❖ **តារាងវិភាគសេដ្ឋកិច្ច <u>ដំឡូងមីក្រៀម</u>** (ដែលបានពីទិន្នផលដំឡូងមីស្រស់៣០តោន/ហិកតា) **នៅខេត្តព្រះវិហារ**

| ប្រភេទចំណាយ | ខ្នាត | ចំនួន (ឯកតា) | តម្លៃ/ឯកតា (រៀល) | សរុប/ហិកតា (ជារៀល) |
|---|---|---|---|---|
| ការរៀបចំដី(ភ្ជួរ រាស់ លើករង) | ឈុត | 1 | 450,000 | 450,000 |
| ជី ១៥ - ១៥- ១៥(ដាក់ពេលពូនរង) | គ.ក | 150 | 3,000 | 450,000 |
| ថ្លៃដាំ | លើក | 1 | 240,000 | 240,000 |
| ពូជ | បាច់ | 250 | 4,000 | 1,000,000 |
| ថ្លៃបាញ់ និងថ្នាំស្មៅ | លើក | 1 | 80,000 | 80,000 |
| ជីបំប៉នលើទី១(អាយុ ៤៥-៧០ថ្ងៃក្រោយដាំ) | គ.ក | 150 | 3,000 | 450,000 |
| ថ្លៃថ្នាំសត្វល្អិត (ពេលដំឡូងអាយុ៣ខែ) | ឈុត | 1 | 75,800 | 75,800 |
| ជីបំប៉នលើទី២ (៩០-១២០ថ្ងៃ ក្រោយដាំ) | គ.ក | 90 | 3,000 | 270,000 |
| ថ្លៃថ្នាំសត្វល្អិត (ពេលដំឡូងអាយុ៤-៥ខែ) | ឈុត | 1 | 75,800 | 75,800 |
| ថ្លៃកាប់ដើម (១បាច់= ២៥ដើម) | បាច់ | 400 | 1,000 | 400,000 |
| ខ្សែចងដើមដំឡូង | ដុំ | 1 | 17,500 | 17,500 |
| ថ្លៃភ្ជួរគាស់មើម | លើក | 1 | 220,000 | 220,000 |
| ឈ្នួលប្រមូលដំឡូង និងលើកដាក់ឡាន១តោន= ៣៥,០០០រៀល (ទិន្នផល ៣០,០០០គ.ក/ហិកតា) | តោន | 30 | 35,000 | 1,050,000 |
| ឈ្នួលចិញ្រ្ចាំ និងហាល តម្លៃ១០០០រៀល/កញ្ចេ ដំឡូងស្រស់ ក្នុង១កញ្ចេទម្ងន់ ២៥គ.ក ទិន្នផល ៣០០០០គ.ក/ហិកតា=១២០០កញ្ចេ | កញ្ចេ | 1200 | 1,000 | 1,200,000 |

| | | | | |
|---|---|---|---|---|
| ថ្លៃប្រមូលដំឡូងក្រៀមច្រកការុងតម្លៃ១០០០រៀល/ការុងទម្ងន់៧៥គ.ក/ការុង(ដំឡូងស្រស់១០០០គ.ក បានដំឡូងក្រៀម ៥៥%=៥៥០ គ.ក)ទិន្នផល ៣០០០០គ.ក ដំឡូងមីស្រស់/ហិកតា ស្មើនឹង ១៦៥០០គ.ក ដំឡូងក្រៀម(៥៥%)ស្មើនឹង២២០ ការុងដំឡូងក្រៀម | ការុង | 220 | 1,000 | 220,000 |
| ថ្លៃការុង | ការុង | 220 | 300 | 66,000 |
| ថ្លៃលើកដាក់ឡាន១តោន=១០,០០០រៀល | តោន | 16.50 | 10,000 | 165,000 |
| ថ្លៃដឹកទៅដល់សែឡូ១តោន=២០,០០០រៀល | តោន | 16.50 | 20,000 | 330,000 |
| **សរុបចំណាយ** | | | | **6,760,100** |
| **ចំណូលពីលក់ដើមដំឡូងមី** | បាច់ | 400 | 4,000 | **1,600,000** |
| **ចំណូលពីលក់ដំឡូងមីចំណិតក្រៀម** | គ.ក | 16,500 | 600 | **9,900,000** |
| **លទ្ធផល** (ចំណេញ / ខាត) | | | | **4,651,400** |

❖ **និន្នាការតម្លៃដំឡូងក្រៀម** (ដំឡូងមីស្រស់ ១,០០០គ.ក= ក្រៀម ៥៥០គ.ក) **នៅខេត្តព្រះវិហារ÷**

| ទិន្នផល (គ.ក/ហិកតា) | តម្លៃ (៛/គ.ក) | និន្នាការចំណូល (រៀល) | ថ្លៃដើម (រៀល/ហិកតា) | ខាត-ចំណេញ (រៀល/ហិកតា) |
|---|---|---|---|---|
| 16,500 | 400 | 6,600,000 | 6,760,100 | -160,100 |
| 16,500 | 450 | 7,425,000 | 6,760,100 | 664,900 |
| 16,500 | 500 | 8,250,000 | 6,760,100 | 1,489,900 |
| 16,500 | 550 | 9,075,000 | 6,760,100 | 2,314,900 |
| 16,500 | 600 | 9,900,000 | 6,760,100 | 3,139,900 |
| 16,500 | 650 | 10,725,000 | 6,760,100 | 3,964,900 |
| 16,500 | 700 | 11,550,000 | 6,760,100 | 4,789,900 |
| 16,500 | 750 | 12,375,000 | 6,760,100 | 5,614,900 |
| 16,500 | 800 | 13,200,000 | 6,760,100 | 6,439,900 |
| 16,500 | 850 | 14,025,000 | 6,760,100 | 7,264,900 |

## ខ. ករណីសិក្សាដំឡូងមីស្រស់នៅខេត្តត្បូងឃ្មុំ

❖ តារាងវិភាគសេដ្ឋកិច្ចដំឡូងមីស្រស់នៅខេត្តត្បូងឃ្មុំ

| ល.រ | ប្រភេទចំណាយ | ឯកតា | ចំនួនឯកតា | តម្លៃ/ឯកតា (រៀល) | សរុប/ហិកតា (ជារៀល) |
|---|---|---|---|---|---|
| ១ | ថ្លៃរៀបចំដី ភ្ជួរ | ឈុត | 1 | 450,000 | 450,000 |
| ២ | ពូជ | បាច់ | 400 | 5,000 | 2,000,000 |
| ៣ | ជី (ជីក្បាលក្របី) ១បេ= ៥០គ.ក | ការុង | 5 | 110,000 | 550,000 |
| ៤ | ថ្លៃកម្លាំងពលកម្មដាំ | ឈុត | 1 | 30,000 | 750,000 |
| ៥ | កម្លាំងពលកម្មធ្វើស្មៅ | នាក់ | 20 | 30,000 | 600,000 |
| ៦ | ថ្នាំស្មៅ (៥លីត្រ/កាន) | កាន | 2 | 45,000 | 90,000 |
| ៧ | អ្នកបាញ់ស្មៅ | នាក់ | 4 | 40,000 | 160,000 |
| ៨ | កម្លាំងប្រមូលផល | នាក់ | 20 | 30,000 | 600,000 |
| ៩ | ថ្លៃដឹកជញ្ជូនពីចម្ការទៅឃ្លាំង | តោន | 35 | 20,000 | 700,000 |
| **ចំណាយសរុប** | | | | | **5,900,000** |
| **ចំណូលពីការលក់មើមដំឡូងស្រស់** | | គ.ក | 35,000 | 200 | **7,000,000** |
| **ចំណូលពីការលក់ពូជដំឡូង** | | បាច់ | 400 | 4,000 | **1,600,000** |
| **លទ្ធផល** (ចំណេញ / ខាត) | | | | | **3,100,000** |

❖ និន្នាការតម្លៃដំឡូងមីស្រស់នៅខេត្តត្បូងឃ្មុំ

| ទិន្នផលស្រស់ (គ.ក / ហ.ត) | និន្នាការតម្លៃ (រៀល/គ.ក) | ចំណូល (រៀល) | ថ្លៃដើម (រៀល) | ខាត/ចំណេញ (រៀល) |
|---|---|---|---|---|
| 35,000 | 160 | 5,600,000 | 5,900,000 | -300,000 |
| 35,000 | 180 | 6,300,000 | 5,900,000 | 400,000 |
| 35,000 | 200 | 7,000,000 | 5,900,000 | 1,100,000 |
| 35,000 | 220 | 7,700,000 | 5,900,000 | 1,800,000 |
| 35,000 | 240 | 8,400,000 | 5,900,000 | 2,500,000 |
| 35,000 | 260 | 9,100,000 | 5,900,000 | 3,200,000 |
| 35,000 | 280 | 9,800,000 | 5,900,000 | 3,900,000 |
| 35,000 | 300 | 10,500,000 | 5,900,000 | 4,600,000 |
| 35,000 | 320 | 11,200,000 | 5,900,000 | 5,300,000 |
| 35,000 | 340 | 11,900,000 | 5,900,000 | 6,000,000 |

## ❖ តារាងវិភាគសេដ្ឋកិច្ចដំឡូងមីក្រៀមនៅខេត្តត្បូងឃ្មុំ

| ប្រភេទចំណាយ | ខ្នាត | ចំនួន (ឯកតា) | តម្លៃ/ឯកតា(រៀល) | សរុប/ហិកតា (ជារៀល) |
|---|---|---|---|---|
| ការរៀបចំដី(ភ្ជួរ រាស់ លើករង) | ឈុត | 1 | 450,000 | 450,000 |
| ជី (ជីក្បាលក្របី) ១ការុង=៥០គ.ក | ការុង | 250 | 4,000 | 1,000,000 |
| ថ្លៃដាំ | ហិកតា | 4 | 110,000 | 440,000 |
| ពូជ | បាច់ | 1 | 240,000 | 240,000 |
| ថ្លៃបាញ់ និងថ្នាំស្មៅ (អាយុ២ខែកន្លះទៅ៣ខែ) | លើក | 20 | 30,000 | 600,000 |
| ជីបំប៉នលើទី១(អាយុ ៤៥-៧០ថ្ងៃក្រោយដាំ) | ការុង | 2 | 45,000 | 90,000 |
| ថ្លៃថ្នាំសត្វល្អិត (ពេលដំឡូងអាយុ៣ខែ) | ឈុត | 4 | 110,000 | 440,000 |
| ជីបំប៉នលើទី២ (៩០-១២០ថ្ងៃ ក្រោយដាំ) | ការុង | 2 | 50,000 | 100,000 |
| ថ្លៃថ្នាំសត្វល្អិត (ពេលដំឡូងអាយុ៤-៥ខែ) | ឈុត | 1 | 600,000 | 600,000 |
| ថ្លៃកាប់ដើម (១បាច់= ២៥ដើម) | បាច់ | | | |
| ខ្សែចងដើមដំឡូង | ដុំ | 400 | 1,000 | 400,000 |
| ថ្លៃភ្ជួរគាស់មើម | លើក | 1 | 17,000 | 17,000 |
| ឈ្នួលប្រមូលដំឡូង និងលើកដាក់ឡាន១តោន= ៣៥,០០០រៀល (ទិន្នផល ៣៥,០០០គ.ក/ហិកតា) | តោន | 1 | 220,000 | 220,000 |
| ឈ្នួលចិញ្ច្រាំ និងហាលតម្លៃ ១,០០០រៀល/កញ្ចេដំឡូងមីស្រស់ ក្នុង១កញ្ចេទម្ងន់ ២៥គ.ក ទិន្នផល ៣៥,០០០គ.ក/ហិកតា=១៤០០កញ្ចេ | កញ្ចេ | 35 | 35,000 | 1,225,000 |
| ថ្លៃប្រមូលដំឡូងក្រៀមច្រកការុងតម្លៃ១,០០០រៀល/ការុង ទម្ងន់៧៥គ.ក/ការុង (ដំឡូងស្រស់១០០០គ.ក បានដំឡូងក្រៀម ៥៥%= ៥៥០ គ.ក)ទិន្នផល ៣៥០០០ គ.ក ដំឡូងមីស្រស់/ហិកតា ស្មើនឹង ១៩២៥០គ.ក ដំឡូងក្រៀម (៥៥%)ស្មើនឹង២៥៧ ការុងដំឡូងក្រៀម | ការុង | 1400 | 1000 | 1,400,000 |
| ថ្លៃការុង | ការុង | 257 | 1000 | 257,000 |
| ថ្លៃលើកដាក់ឡាន១តោន=១០,០០០រៀល | តោន | 257 | 400 | 102,800 |
| ថ្លៃដឹកទៅដល់សៃឡូ១តោន=២០,០០០រៀល | តោន | 19.25 | 10000 | 192,500 |
| **សរុបចំណាយ** | | | | **7,774,300** |
| **ចំណូលពីការលក់ដើមដំឡូងមីសរុប** | បាច់ | 400 | 4,000 | **1,600,000** |
| **ចំណូលពីការលក់ដំឡូងមីចំណិតក្រៀម** | គ.ក | 19,250 | 650 | **12,512,500** |
| **លទ្ធផល** (ចំណេញ/ខាត) | | | | **5,938,200** |

❖ និន្នាការតម្លៃដំឡូងមីក្រៀម (១,០០០ គ.ក ស្រស់= ៥៥០គ.ក ក្រៀម) នៅខេត្តត្បូងឃ្មុំ

| ទិន្នផលដំឡូងក្រៀម (គ.ក/ហ.ត) | តម្លៃឯកតា (រៀល/គ.ក) | ចំណូល (រៀល) | ថ្លៃដើម (រៀល/ហ.ត) | ខាត-ចំណេញ (រៀល/ហ.ត) |
|---|---|---|---|---|
| 19,250 | 400 | 7,700,000 | 7,774,300 | -74,300 |
| 19,250 | 450 | 8,662,500 | 7,774,300 | 888,200 |
| 19,250 | 500 | 9,625,000 | 7,774,300 | 1,850,700 |
| 19,250 | 550 | 10,587,500 | 7,774,300 | 2,813,200 |
| 19,250 | 600 | 11,550,000 | 7,774,300 | 3,775,700 |
| 19,250 | 650 | 12,512,500 | 7,774,300 | 4,738,200 |

## គ. ករណីសិក្សាដំឡូងមីនៅខេត្តបាត់ដំបង

❖ តារាងវិភាគសេដ្ឋកិច្ចដំឡូងមីស្រស់នៅសំឡូត ខេត្តបាត់ដំបង

| ប្រភេទចំណាយ | ឯកតា | ចំនួន/ឯកតា | តម្លៃ/ឯកតា (រៀល) | សរុប/ហិកតា (រៀល) |
|---|---|---|---|---|
| ការរៀបចំដី(ភ្ជួរ រាស់ លើករង) | ឈុត | 1 | 500,000 | 500,000 |
| ជី ២០x ២០x ១៥ដាក់ពេលពូនរង | គ.ក | 200 | 2,600 | 520,000 |
| ថ្លៃដាំ | ហិកតា | 1 | 200,000 | 200,000 |
| ពូជ | បាច់ | 250 | 3,000 | 750,000 |
| ថ្លៃបាញ់ស្មៅ | លើក | 2 | 55,000 | 110,000 |
| ថ្នាំប៉ូវ | ឈុត | 2 | 150,000 | 300,000 |
| ថ្លៃកាប់ដើម (១បាច់= ២៥ដើម) | បាច់ | 400 | 1,000 | 400,000 |
| ខ្សែចងដើមដំឡូង | ដុំ | 1 | 17,000 | 17,000 |
| ថ្លៃភ្ជួរគាស់មើម | ហិកតា | 1 | 150,000 | 150,000 |
| ឈ្នួលប្រមូលដំឡូង និងលើកដាក់ឡាន១តោន= ៣៥,០០០រៀល (ទិន្នផល ៣០តោន/ហិកតា) | តោន | 30 | 35,000 | 1,050,000 |
| ថ្លៃដឹកទៅដល់សែឡ (១តោន= ២៥,០០០រៀល) | តោន | 30 | 25,000 | 750,000 |
| **សរុបចំណាយ** | | | | **4,747,000** |
| **ចំណូលពីការលក់ដំឡូងមីស្រស់** (តម្លៃនៅដើមឆ្នាំ២០២៥ ពី២៥០រៀល/គ.ក) | តោន | 30,000 | 250 | **7,500,000** |
| **ចំណូលពីការលក់ដើមដំឡូងមី** | បាច់ | 250 | 3,000 | **750,000** |
| **លទ្ធផល** (ចំណេញ / ខាត) | | | | **3,503,000** |

## ❖ និន្នាការតម្លៃនៃទិន្នផលដំឡូងមីស្រស់៣០តោន/ហិកតានៅសំឡូត ខេត្តបាត់ដំបង

| ទិន្នផលមើមដំឡូងមីស្រស់ (គ.ក/ហ.ត) | តម្លៃឯកតា (រៀល/គ.ក) | ចំណូល (រៀល) | ថ្លៃដើម (រៀល/ហ.ត) | ខាត/ចំណេញ (រៀល/ហ.ត) |
|---|---|---|---|---|
| 30,000 | 140 | 4,200,000 | 4,747,000 | -547,000 |
| 30,000 | 150 | 4,500,000 | 4,747,000 | -247,000 |
| 30,000 | 160 | 4,800,000 | 4,747,000 | 53,000 |
| 30,000 | 170 | 5,100,000 | 4,747,000 | 353,000 |
| 30,000 | 180 | 5,400,000 | 4,747,000 | 653,000 |
| 30,000 | 190 | 5,700,000 | 4,747,000 | 953,000 |
| 30,000 | 200 | 6,000,000 | 4,747,000 | 1,253,000 |
| 30,000 | 210 | 6,300,000 | 4,747,000 | 1,553,000 |
| 30,000 | 220 | 6,600,000 | 4,747,000 | 1,853,000 |
| 30,000 | 230 | 6,900,000 | 4,747,000 | 2,153,000 |
| 30,000 | 240 | 7,200,000 | 4,747,000 | 2,453,000 |
| 30,000 | 250 | 7,500,000 | 4,747,000 | 2,753,000 |
| 30,000 | 260 | 7,800,000 | 4,747,000 | 3,053,000 |
| 30,000 | 270 | 8,100,000 | 4,747,000 | 3,353,000 |
| 30,000 | 280 | 8,400,000 | 4,747,000 | 3,653,000 |
| 30,000 | 290 | 8,700,000 | 4,747,000 | 3,953,000 |
| 30,000 | 300 | 9,000,000 | 4,747,000 | 4,253,000 |

## ❖ តារាងវិភាគសេដ្ឋកិច្ចដំឡូងក្រៀមនៅសំឡូត ខេត្តបាត់ដំបង

| ប្រភេទចំណាយ | ឯកតា | ចំនួន/ឯកតា | តម្លៃ (រៀល/ឯកតា) | តម្លៃសរុប (រៀល/ហិកតា) |
|---|---|---|---|---|
| ការរៀបចំដី(ភ្ជួរ រាស់ លើករង) | ឈុត | 1 | 500,000 | 500,000 |
| ជី ២០-២០-១៥ | គ.ក | 200 | 2,600 | 520,000 |
| ថ្លៃដាំ | លើក | 1 | 200,000 | 200,000 |
| ពូជ | បាច់ | 250 | 3,000 | 750,000 |
| ថ្លៃបាញ់ស្មៅ និងបោចស្មៅតាមគល់ | លើក | 2 | 550,00 | 1,100,00 |
| ថ្នាំប៉ូវ | ឈុត | 3 | 150,000 | 300,000 |
| ថ្លៃកាប់ដើម (១បាច់=២៥ដើម) | បាច់ | 400 | 1,000 | 250,000 |
| ខ្សែចងដើមដំឡូង | ដុំ | 1 | 17,000 | 17,000 |
| ថ្លៃភ្ជួរគាស់មើម | លើក | 1 | 150,000 | 150,000 |

| | | | | |
|---|---|---|---|---|
| ឈ្នួលចិញ្ច្រាំ និងហាល តម្លៃ១០០០រៀល/កញ្ចេ ដំឡូងស្រស់ ក្នុង១កញ្ចេទម្ងន់ ២៥គ.ក | កញ្ចេ | 1200 | 1,000 | 1,200,000 |
| ថ្លៃដឹកទៅដល់សែឡូ (១តោន=២៥០០០រៀល) | តោន | 220 | 25,000 | 750,000 |
| ថ្លៃប្រមូលដំឡូងក្រៀមច្រកការុងតម្លៃ១០០០រៀល/ការុង ទម្ងន់៧៥គ.ក/ការុង( ដំឡូងស្រស់ ១០០០គ.ក បានដំឡូងក្រៀម ពី៥៥%=៥៥០គ.ក)ទិន្នផល ៣០តោន ដំឡូងមីស្រស់/ហិកតា ស្មើនឹង ១៦៥០០គ.ក ដំឡូងក្រៀម(៥៥%) ស្មើនឹង២២០ការុងដំឡូងមីក្រៀម | ការុង | 220 | 1000 | 220,000 |
| ថ្លៃការុង | ការុង | 16.50 | 220 | 88,000 |
| ថ្លៃលើកដាក់ឡាន១តោន=១០,០០០រៀល | តោន | 16.50 | 10000 | 165,000 |
| ថ្លៃដឹកទៅដល់សែឡូ១តោន=២០,០០០រៀល | តោន | 1 | 20000 | 330,000 |
| **សរុបចំណាយ** | | | | **5,420,000** |
| **ចំណូលពីការលក់ដើមដំឡូងមី** | គ.ក | 250 | 3,000 | **750,000** |
| **ចំណូលពីការលក់ដំឡូងមីចំណិតក្រៀម** (តម្លៃនៅដើមឆ្នាំ២០២៥ គឺ៦០០រៀលក្នុងគ.ក) | គ.ក | 16,500 | 600 | **9,900,000** |
| **លទ្ធផល** (ចំណេញ / ខាត) | | | | **5,230,000** |

❖ **និន្នាការតម្លៃដំឡូងមីក្រៀម** (១,០០០គ.ក ស្រស់ = ៥៥០គ.ក ក្រៀម)
**នៅស្រុកសំឡូត ខេត្តបាត់ដំបង**

| ទិន្នផលដំឡូងក្រៀម (គ.ក/ហ.ត) | តម្លៃឯកតា (រៀល/គ.ក) | ចំណូល (រៀល) | ថ្លៃដើម (រៀល/ហ.ត) | ខាត-ចំណេញ (រៀល/ហ.ត) |
|---|---|---|---|---|
| 16,500 | 350 | 5,775,000 | 5,420,000 | 355,000 |
| 16,500 | 400 | 6,600,000 | 5,420,000 | 1,180,000 |
| 16,500 | 450 | 7,425,000 | 5,420,000 | 2,005,000 |
| 16,500 | 500 | 8,250,000 | 5,420,000 | 2,830,000 |
| 16,500 | 550 | 9,075,000 | 5,420,000 | 3,655,000 |
| 16,500 | 600 | 9,900,000 | 5,420,000 | 4,480,000 |
| 16,500 | 650 | 10,725,000 | 5,420,000 | 5,305,000 |
| 16,500 | 700 | 11,550,000 | 5,420,000 | 6,130,000 |
| 16,500 | 750 | 12,375,000 | 5,420,000 | 6,955,000 |
| 16,500 | 800 | 13,200,000 | 5,420,000 | 7,780,000 |
| 16,500 | 850 | 14,025,000 | 5,420,000 | 8,605,000 |

## ៦-បញ្ហាប្រឈម

តាមបទពិសោធន៍លើការដាំដំណាំឡូងមីរបស់កសិករនៅខេត្តព្រះវិហារ ត្បូងឃ្មុំ និងបាត់ដំបង ក្រុមការងារនៃ ធ.អ.ជ.ក សង្កេតឃើញថា កសិករអាចជួបបញ្ហាប្រឈម និងហានិភ័យមួយចំនួនដូចជា÷

| ប្រភេទហានិភ័យ | បញ្ហាប្រឈម | ដំណោះស្រាយ |
|---|---|---|
| **ហានិភ័យផលិតកម្ម** | កត្តាសត្វល្អិតចង្រៃ | -ត្រូវត្រួតពិនិត្យសត្វល្អិតជាប្រចាំជាពិសេសចាប់ផ្តើមពីការលូតលាស់ចេញត្រួយដំបូងនៃដំណាំដំឡូងមី<br>-កាត់បន្ថយការប្រើប្រាស់អាសូតច្រើនហួសកម្រិតដែលអាចទាក់ទាញសត្វល្អិតមកបំផ្លាញខ្លាំង<br>-ស្រោចស្រពទឹក និងដាក់ជីឱ្យបានគ្រប់គ្រាន់ ដើម្បីមានភាពធន់ទៅនឹងសត្វល្អិតចង្រៃ<br>-ប្រើប្រាស់ពូជដំឡូងមីដែលធន់នឹងសត្វល្អិតចង្រៃ<br>-ប្រើប្រាស់វិធានការចម្រុះការពារដំណាំ (IPM) ដូចជា÷ បំបាត់ជម្រកសត្វល្អិតចង្រៃ -ប្រើប្រដាទ់រ និងថ្នាំគីមី។ |
| | ជំងឺ | -ដាក់ជី និងទឹកមានតុល្យភាព នាំឱ្យដំណាំធន់នឹងជំងឺ<br>-ប្រើពូជដំឡូងមីដែលធន់ជំងឺ និងមិនមានផ្ទុកជំងឺ<br>-ត្រូវស្គាល់ប្រភពពូជឱ្យបានច្បាស់មុនយកមកដាំ<br>-កុំឱ្យដីចម្ការដក់ទឹករយៈពេលយូរ<br>-ប្រើប្រាស់ថ្នាំជីវសាស្ត្រ និងគីមីតាមភាពចាំបាច់។ |
| | ដីខ្សោះជីជាតិ | - កែលម្អគុណភាពដី (ដោយប្រើជីសរីរាង្គ និងគីមី)<br>- ដំណាំបង្វិល ដំណាំឆ្លាស់<br>- វិភាគដី និងតាមដានគុណភាពដី<br>- ដាំដំណាំគម្របដី<br>- បន្ថយការភ្ជួរដីញឹកញាប់ |
| | ការប្រែប្រួលអាកាសធាតុ (រាំងស្ងួត ទឹកជំនន់) | - ត្រៀមទឹកសម្រាប់ពេលរាំងស្ងួតយូរ (ត្រូវមានប្រភពទឹក និងប្រព័ន្ធទឹកបម្រុង)<br>- បង្ហូរទឹកចេញ ឬដាំលើដីដែលមិនងាយលិចទឹក ឬដីងាយស្រស់ទឹកឆាប់រហ័ស |

| | | |
|---|---|---|
| **ហានិភ័យទីផ្សារ** | ការប្រែប្រួលតម្លៃដំឡូងមី | -បង្កើតជាសហគមន៍កសិកម្ម ផលិតកម្មតាមកិច្ចសន្យា<br>-ស្វែងរកអ្នកបញ្ជាទិញ ឈ្មួញកណ្តាល ដែលមានក្រម សីលធម៌ ស្មោះត្រង់ និងសុចរិតភាព<br>-ស្រាវជ្រាវនិន្នាការព័ត៌មានទីផ្សារក្នុងស្រុក និងក្រៅស្រុកជាប្រចាំ។ |
| **ហានិភ័យ ហិរញ្ញវត្ថុ** | ការចំណាយក្នុង ការចាប់ផ្តើមដាំ | -ត្រូវរៀបចំផែនការហិរញ្ញវត្ថុ ផលិតកម្មដំណាំដំឡូងមី<br>-ត្រៀមថវិកាបម្រុងសម្រាប់ការបូមទឹកស្រោចស្រព ពេលជួបគ្រោះរាំងស្ងួតខ្លាំងរយៈពេលពី ៣-៦ខែ ដំបូង<br>-កត់ត្រាបញ្ជីចំណាយ-ចំណូលឱ្យបានច្បាស់លាស់ និង កាត់បន្ថយការចំណាយដែលមិនចាំបាច់។ |
| | ការឡើងថ្លៃនៃធាតុចូល កសិកម្មលើសពីការគ្រោងទុក | -ជ្រើសរើសអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្មដែលទុកចិត្ត<br>-ប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងតំបន់ដើម្បីជួយ កាត់បន្ថយការចំណាយ ដូចជាការធ្វើជីកំប៉ុសដោយខ្លួន ឯងជាដើម។ |

## ៧.អនុសាសន៍សម្រាប់កសិករដាំដំឡូងមី

ដើម្បីកាត់បន្ថយហានិភ័យ និងបង្កើនប្រសិទ្ធភាពក្នុងការដាំដុះដំឡូងមី កសិករគួរពិចារណាអនុវត្ត អនុសាសន៍សំខាន់ៗមួយចំនួនដូចខាងក្រោម÷

-ជ្រើសរើសពូជធន់÷ ប្រើប្រាស់**ពូជដំឡូងមីដែលធន់នឹងជំងឺម៉ូសាអ៊ិក** (Cassava Mosaic Disease) និង សត្វល្អិតចង្រៃ។ ពូជទាំងនេះត្រូវបានស្រាវជ្រាវ និងណែនាំដោយក្រសួងកសិកម្ម ឬអង្គការដៃគូ។ ឧទាហរណ៍ ពូជKU50 ធន់នឹងជំងឺម៉ូសាអ៊ិក ហើយត្រូវបានណែនាំឱ្យកសិករដាំ។

-រៀបចំដីឱ្យបានត្រឹមត្រូវ÷ ភ្ជួររាស់ដីឱ្យបានជ្រៅ និងធ្វើដីម៉ដ្ឋល្អ ដើម្បីឱ្យដីធូរហើយសម្បូរខ្យល់ចេញ ចូល។ ការលើកដីពូនរងដំឡូងក៏សំខាន់ដែរ ព្រោះវាជួយកាត់បន្ថយបញ្ហាលិចទឹកនៅរដូវវស្សា និងជួយឱ្យ មើមដំឡូងធំធាត់បានល្អ។

-វិភាគដី÷ មុននឹងដាំ គួរធ្វើការវិភាគដីដើម្បីដឹងពីកម្រិតជីជាតិដី និងកែតម្រូវជាតិអាស៊ីត-បាស (pH) របស់ដីឱ្យសមស្រប(ដំឡូងមីលូតលាស់ល្អនៅpH 5.5-7.0)។

-កាត់បន្ថយចំណាយលើការប្រើប្រាស់ជីគីមី÷ គួរប្រើប្រាស់ **ជីសរីរាង្គ** បន្ថែម ឬជំនួសជីគីមីមួយផ្នែក។ ជីកំប៉ុស្ត ឬលាមកសត្វអាចជួយបង្កើនជីជាតិដី រក្សាសំណើម និងកាត់បន្ថយការពឹងផ្អែកលើជីគីមីដែលមាន តម្លៃខ្ពស់។

-គ្រប់គ្រងទឹក៖ ដំឡូងមីត្រូវការទឹកគ្រប់គ្រាន់ ប៉ុន្តែមិនត្រូវការទឹកដក់ទេ។ កសិករគួរពិចារណាលើការរៀបចំប្រព័ន្ធធារាសាស្ត្រសាមញ្ញៗ ដើម្បីធានាថាដំណាំទទួលបានសំណើមគ្រប់គ្រាន់នៅក្នុងរដូវប្រាំង និងមិនលិចទឹកក្នុង រដូវវស្សា។

-កម្ចាត់ស្មៅ៖ ស្មៅប្រកួតប្រជែងជាមួយដើមដំឡូងមីស្រូបយកជីជាតិ និងទឹក។ កសិករគួរកម្ចាត់ស្មៅឱ្យបានទៀងទាត់ ជាពិសេសក្នុងដំណាក់កាលដំបូងនៃការលូតលាស់របស់ដំណាំដំឡូងមី។

-តាមដាន និងគ្រប់គ្រងជំងឺ-សត្វល្អិតចង្រៃ៖ ពិនិត្យមើលដំណាំជាប្រចាំដើម្បីរកសញ្ញានៃជំងឺ ឬសត្វល្អិតចង្រៃ។ ត្រូវចាត់វិធានការទប់ស្កាត់ឱ្យបានទាន់ពេលវេលា ដោយប្រើប្រាស់ថ្នាំកសិកម្មតាមកម្រិតណែនាំ ឬវិធីសាស្ត្រធម្មជាតិ។

-ពិពិធកម្មដំណាំ(ដាំដំណាំឱ្យបានច្រើនមុខ)៖សូមកសិករកុំពឹងផ្អែកតែលើដំណាំដំឡូងមីតែមួយមុខ។ កសិករគួរពិចារណាដាំដំណាំរួមផ្សំផ្សេងៗទៀតដែលមានសក្តានុពលទីផ្សារល្អ ឬដាំដំណាំឆ្លាស់គ្នាដើម្បីកាត់បន្ថយហានិភ័យនៅពេលតម្លៃដំឡូងមីធ្លាក់ចុះ។

-ស្វែងរកទីផ្សារ និងកិច្ចសន្យាដាំដុះ៖ ព្យាយាមរកទំនាក់ទំនងផ្ទាល់ជាមួយរោងចក្រកែច្នៃ ឬក្រុមហ៊ុនធំៗសម្រាប់ការលក់ផលិតផលដោយផ្ទាល់ និងអាចទទួលបានតម្លៃប្រសើរជាងមុន ក៏ដូចជាអាចធ្វើកិច្ចសន្យាដាំដុះ (Contract Farming) ដើម្បីធានាទីផ្សារតម្លៃ។

-កែច្នៃបឋម៖ បើសិនជាអាច កសិករគួរធ្វើការកែច្នៃបឋម (ឧទាហរណ៍ ហាលស្ងួតជាដំឡូងចំណិត) ដើម្បីរក្សាទុកបានយូរ និងងាយស្រួលលក់នៅពេលតម្លៃទីផ្សារល្អ។

-ចូលរួមជាក្រុម ឬសហគមន៍៖ ការចូលរួមជាក្រុម ឬសហគមន៍កសិករ អាចជួយឱ្យមានអំណាចក្នុងការចរចាជាមួយឈ្មួញធំៗ ក៏ដូចជាអាចផ្លាស់ប្តូរបទពិសោធន៍ និងទទួលបានព័ត៌មានពីគ្នាទៅវិញទៅមក។

-គ្រប់គ្រងហិរញ្ញវត្ថុ៖ រៀបចំផែនការចំណូល-ចំណាយឱ្យបានច្បាស់លាស់។ ការខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុតែនៅពេលចាំបាច់បំផុតប៉ុណ្ណោះ និងត្រូវប្រាកដថាមានលទ្ធភាពសងត្រឡប់។

-រៀនសូត្រពីអ្នកជំនាញ៖ ចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលស្តីពីបច្ចេកទេសដាំដុះដំឡូងមី និងការគ្រប់គ្រងហានិភ័យ។

-ប្រើប្រាស់ព័ត៌មានអាកាសធាតុ៖ តាមដានព័ត៌មានអាកាសធាតុជាប្រចាំ ដើម្បីរៀបចំផែនការដាំដុះ និងប្រមូលផលឱ្យបានទាន់ពេលវេលា។

ការអនុវត្តអនុសាសន៍ទាំងនេះនឹងជួយឱ្យកសិករដំឡូងមីអាចដាំដុះប្រកបដោយប្រសិទ្ធភាពខ្ពស់ កាត់បន្ថយហានិភ័យ ជួយបង្កើនប្រាក់ចំណូល ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារកាន់តែប្រសើរឡើង។

## ៨-សេចក្តីសន្និដ្ឋាន

តាមរយៈការវិភាគសេដ្ឋកិច្ចលើការដាំដំឡូងមីនៅខេត្តព្រះវិហារ ត្បូងឃ្មុំ និងខេត្តបាត់ដំបង បង្ហាញថាកសិករអ្នកដាំដំឡូងមីអាចទទួលផលចំណេញបានច្រើននៅពេលដែលដំណើរការផលិតកម្មមានប្រើប្រាស់ការចំណាយដែលមានប្រសិទ្ធភាព ដោយមិនចំណាយលើសកម្រិត។ ក្នុងករណីតម្លៃដំឡូងមីស្រស់ចន្លោះ ៣០០-៣៣០រៀល/គីឡូក្រាម និងដំឡូងមីក្រៀមចន្លោះពី៦៥០-៧០០រៀលគីឡូក្រាមឡើងទៅ ទើបកសិករអាចទទួលផលចំណេញបានសមរម្យ។ ដើម្បីទទួលបាននូវតម្លៃល្អ កសិករត្រូវស្រាវជ្រាវពីនិន្នាការតម្លៃលើទីផ្សារ ការផ្គត់ផ្គង់ ទាំងក្នុងស្រុក និងប្រទេសជិតខាង ពីភាគីពាក់ព័ន្ធដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្មជាដើម។

## ៩.ប្រភពឯកសារៈ


១-បទពិសោធន៍របស់កសិករដាំដុះដំណាំដំឡូងមីនៅខេត្តព្រះវិហារ ត្បូងឃ្មុំ និងខេត្តបាត់ដំបង

២- កសិកររបស់សមាគមន៍ដំឡូងមីខេត្តកំពង់ធំ

៣-ដំណាំដំឡូងមីដោយអគ្គនាយកដ្ឋានកសិកម្ម ២០១៦ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤-សៀវភៅស្តីពីដំណាំដំឡូងមីដោយសហប្រតិបត្តិការត្រីភាគីចិន កម្ពុជា UNDP លើការបង្កើនផលិតភាពដំណាំដំឡូងមី, ឆ្នាំ២០១៥

៥-https://www.google.com/search?q=Thrips+on+cassava&client=firefox-b

៦- https://www.google.com/search?client=firefox-b-d&q=Cassava+Brown

៧-https://www.google.com/search?sca_esv=cc5939a42d82a808&q=witches+broom

៨- ដំណាំដំឡូងមី -ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៤